**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជានៅផ្សារតូច**
**ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៨**
***ខ្ញុំមកដោយនាមព្រះជាម្ចាស់***

អត្ថបទទី១៖ អគ ២,២-៥
អត្ថបទទី២៖ ២ករ ១២,៧-១០
ដំណឹងល្អ៖ មក ៦,១-៦

បងប្អូនជាទីស្រឡាញ់!

ព្រះយេស៊ូជាជាងឈើ ដែលណែនាំឲ្យមនុស្សគេឆ្ងល់ថាមូលហេតុអ្វីជាងឈើអាចទៅជាអ្នកដែលប្រកាសដំណឹងល្អ និងទេសនានៅក្នុងធម្មសាលា? ព្រះយេស៊ូមានព្រះបន្ទូលថា "**ខ្ញុំមកដោយនាមព្រះជាម្ចាស់**" យើងយល់ថាព្រះយេស៊ូដែលជាជាងឈើ ដែលជាកូនរបស់នាងម៉ារីដែលជាមនុស្សធម្មតាគេស្គាល់ព្រះយេស៊ូ ប៉ុន្តែនៅពេលនេះព្រះយេស៊ូចាប់ផ្តើមប្រកាសដំណឹងល្អ ជាមូលហេតុធ្វើឲ្យគេពិបាកទទួល។ ណែនាំឲ្យយើងត្រូវតែគិត៖

**ទីមួយ** អំពីរបៀបដែលយើងអាចទទួលព្រះយេស៊ូនៅក្នុងជីវិតរបស់យើង **តើយើងចេះមើលឃើញព្រះយេស៊ូដែលកំពុងធ្វើដំណើរដើម្បីណែនាំជីវិតឬទេ?** វត្តមានរបស់ព្រះយេស៊ូនៅក្នុងដួងចិត្តរបស់យើង នៅក្នុងព្រះបន្ទូល នៅក្នុងព្រះកាយនិងព្រះលោហិត នោះជាព្រះយេស៊ូផ្ទាល់។ បន្ទាប់ពីយើងទទួលព្រះកាយ ពេលយើងទៅអង្គុយវិញឲ្យយើងនឹកឃើញថាព្រះកាយនេះជាព្រះយេស៊ូ ដែលប្រទានជីវិតឲ្យខ្ញុំ។ នំប៉័ងតូចនេះ ជាព្រះយេស៊ូដែលណែនាំឲ្យខ្ញុំពោរពេញដោយសេចក្តីសង្ឃឹម នំប៉័ងតូចនេះ ជាវត្តមានរបស់ព្រះយេស៊ូណែនាំឲ្យខ្ញុំភ្ជាប់ជាមួយព្រះយេស៊ូ។

**ទីពីរ** របៀបដែលយើងមើលមិនស្គាល់ព្រះយេស៊ូគ្រីស្ត កុំឲ្យយើងវិនិច្ឆ័យអ្នកដទៃលឿនពេក កុំឲ្យយើងផាត់ពណ៌ដល់អ្នកដទៃលឿនពេក។ ផ្ទុយទៅវិញឲ្យយើងចូលនៅក្នុងជីវិតរបស់គេដើម្បីឲ្យយើងយល់ពីគេ ដើម្បីមើលសមត្ថភាពរបស់គេ ដើម្បីទទួលស្គាល់ថាព្រះយេស៊ូអាចណែនាំឲ្យមនុស្សម្នាក់ឲ្យរីកចម្រើននៅក្នុងជីវិតពិតមែន ដោយសារព្រះយេស៊ូយាងមកដើម្បីឲ្យយើងកែប្រែចិត្តគំនិត។ បើយើង ណែនាំឲ្យមនុស្សម្នាក់ភ្ជាប់នៅក្នុងគំនិតអាក្រក់ដែលយើងមានអំពីគាត់ គាត់ឥតមាឱកាសដើម្បីធ្វើជាមនុស្សថ្មីតាមរបៀបព្រះយេស៊ូ។ ឲ្យយើងចេះទទួលស្គាល់ព្រះយេស៊ូនៅក្នុងជីវិតរបស់យើង ឲ្យយើងចេះមើលបងប្អូនឯទៀតៗ ដោយសារមនុស្សយើងពោរពេញដោយសមត្ថភាពដែលមកពីព្រះជាម្ចាស់ ហើយអាចណែនាំឲ្យមនុស្សម្នាក់ៗទៅជាមនុស្សថ្មីដោយសារជំនឿ។ នៅពេលព្រះយេស៊ូឃើញរបៀបគេ ព្រះអង្គនឹកឆ្ងល់ដោយសារឃើញគេគ្មានជំនឿបែបនេះ។ ដើម្បីទទួលស្គាល់ព្រះយេស៊ូពិតមែន យើងមិនអាចមើលឃើញដោយភ្នែកធម្មតាទេ ប៉ុន្តែដោយសារជំនឿ នៅពេលលោកសិលាបានឆ្លើយ "**លោកជាព្រះបុត្រា**

របស់ព្រះជាម្ចាស់ លោកជាព្រះគ្រីស្ទ" ព្រះយេស៊ូឆ្លើយថា "**ចម្លើយនេះមិនមែនលោកឆ្លើយដោយខ្លួនឯង ប៉ុន្តែលោកឆ្លើយដោយសារជំនឿ**" ជំនឿដែលបានទទួលពីព្រះបិតា។ មនុស្សយើងខ្វះជំនឿដើម្បីទទួលស្គាល់ថាព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់យ៉ាងពិតប្រាកដមែន។ ព្រះយេស៊ូបានធ្វើដំណើរពីភូមិមួយទៅភូមិមួយ មុនទៅដល់ណាសារ៉ែត នៅគ្រប់ភូមិដែលព្រះយេស៊ូបានទៅ ព្រះយេស៊ូបានជួបជាមួយអ្នកជំងឺ ជួបជាមួយស្ត្រីដែលធ្លាក់ឈាម ជួបជាមួយជនពិការ ជួបជាមួយអ្នកដែលអស់សង្ឃឹមនៅក្នុងជីវិត មុនពេលព្រះយេស៊ូប្រោសឲ្យគេបានជាសះស្បើយ ព្រះអង្គឈ្វេងយល់ជំនឿរបស់គេ។ គ្រប់ពេលវេលា ព្រះយេស៊ូមានព្រះបន្ទូលថា "**សូមទៅចុះ! ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ**" អ្វីៗទាំងអស់មកពីជំនឿ។ នៅពេលយើងអធិដ្ឋាន យើងសុំឲ្យព្រះជាម្ចាស់ជួយឲ្យជំនឿរបស់យើងរីកចម្រើនបន្តិចម្តងៗ ដើម្បីឲ្យយើងមានសមត្ថភាពទទួលស្គាល់ព្រះយេស៊ូយ៉ាងពិតប្រាកដ នឹងយើងមានសមត្ថភាពទទួលជីវិតថ្មីសម្រាប់យើងដែរ ដោយសារជំនឿដែលយើងមាននៅលើព្រះជាម្ចាស់។ ជំនឿ មានន័យថាយើងសុខចិត្តផ្ញើជីវិតទាំងស្រុងលើព្រះអង្គ ដោយដឹងថាយើងមានទីពឹងតែមួយគឺព្រះជាម្ចាស់។ ពេលខ្ញុំបានធ្វើជំហានទីមួយនៅតាកែវសប្តាហ៍មុន ចំនួន៧០នាក់ គេបានប្រកាសខ្ញុំទន្ទឹងរង់ចាំពីព្រះសហគមន៍គឺជំនឿ ជំនឿណែនាំឲ្យខ្ញុំទទួលជីវិតអស់កល្បជានិច្ច ហេតុនេះហើយខ្ញុំយកព្រះគ្រីស្ទ ខ្ញុំយកព្រះបន្ទូល ខ្ញុំយកព្រះសហគមន៍ជាទីពឹង ដោយសារខ្ញុំដឹងថាព្រះយេស៊ូចាប់ផ្តើមធ្វើដំណើរជាមួយខ្ញុំ ហើយខ្ញុំចង់ទទួលជីវិតថ្មីនៅថ្ងៃដែលខ្ញុំទទួលអគ្គសញ្ញាជ្រមុជទឹក។ ពេលយើងបានទទួលអគ្គសញ្ញាជ្រមុជទឹកហើយ យើងសុំជំនឿបន្ថែមអស់មួយជីវិត ដើម្បីឲ្យព្រះយេស៊ូមានព្រះបន្ទូលដល់ខ្ញុំផ្ទាល់ថា "**សូមទៅចុះ! ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ**"។ លោកប៉ូលបាននិយាយថា "**ការប្រោសប្រណីរបស់យើង ល្មមគ្រប់គ្រាន់សម្រាប់អ្នកហើយ**" មានន័យថាព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ល្មមសម្រាប់ជីវិតរបស់ខ្ញុំហើយ។ ប្រសិនបើខ្ញុំទទួលស្គាល់ថា ពិតមែនព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ ព្រះជាម្ចាស់លើកលែងទោសឲ្យខ្ញុំ ខ្ញុំមានបទពិសោធន៍នៃព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គក្នុងជីវិតខ្ញុំ ល្មមហើយ។ ពេលយើងភ្ជាប់ជាមួយព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ពេលយើងដឹងថាព្រហជាម្ចាស់លើកលែងទោសឲ្យយើងពិតមែន ដើម្បីឲ្យយើងធ្វើជាមនុស្សថ្មី យើងមិនត្រូវការអ្វីទៀតទេព្រោះយើងដល់កំពូលហើយ។ ជីវិតរបស់យើងជាគ្រីស្តបរិស័ទឡើងដល់កំពូល នៅពេលយើងអាចនិយាយថា"**ពិតមែនខ្ញុំយកព្រះគ្រីស្ទជាទីពឹងនៃជីវិតរបស់ខ្ញុំ**" មិនមែននិយាយតែបបូរមាត់ ប៉ុន្តែនិយាយដោយអស់ពីដួងចិត្ត អស់ពីជំនឿ អស់ពីសេចក្តីស្រឡាញ់របស់យើង ដោយយល់ថាព្រះជាម្ចាស់បំពេញជីវិតរបស់ខ្ញុំ ព្រះជាម្ចាស់ជាអាទិភាពសម្រាប់ជីវិតរបស់ខ្ញុំ។ ពេលយើងចូលនៅក្នុងព្រះវិហាររាល់សប្តាហ៍ ជាពេលវេលាដែលយើងទទួលកម្លាំងនោះ។ សព្វថ្ងៃយើងរស់នៅក្នុងជីវិតធម្មតា ប៉ុន្តែជីវិតធម្មតារបស់យើងជា

ជីវិតដល់កំពូលដោយសារយើងមានព្រះយេស៊ូដែលជួយលើកទឹកចិត្ត ផ្តល់កម្លាំង ណែនាំខ្ញុំឲ្យខ្ញុំដឹងខុស និងឲ្យខ្ញុំដឹងត្រូវ។ ព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ល្មមគ្រប់គ្រាន់សម្រាប់ខ្ញុំយើងចាប់ផ្តើមឡើងដល់កំពូល។ ព្រះជាម្ចាស់មានព្រះបន្ទូលថា "**កូនមនុស្សអើយ! យើងចាត់អ្នកឲ្យទៅរកជនជាតិអ៊ីស្រាអែល គឺទៅរកប្រជាតិដែលបះបោរប្រឆាំងនឹងយើង**" បេសកកម្មដែលយើងទទួលគឺយើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទៅប្រមូលមនុស្សដែលមិនស្គាល់ព្រះជាម្ចាស់ មនុស្សដែលប្រឆាំងជាមួយព្រះជាម្ចាស់ឲ្យគេដើរមករកព្រះជាម្ចាស់វិញ។

យើងអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ សូមព្រះយេស៊ូដែលយាងមកជួយណែនាំឲ្យមនុស្សទទួលជីវិតថ្មីតាមរយៈការបូជាជីវិត តាមរយៈការសោយទិវង្គតនៅលើឈើឆ្កាងនិងមានព្រះជន្មរស់ឡើងវិញទៅជាជីវិតរបស់យើង។ ឲ្យយើងស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ ដែលកំពុងណែនាំឲ្យយើងទទួលកំពូលនៃជីវិតរបស់យើង តាមព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ដើម្បីចាត់ឲ្យយើងទៅប្រកាសដំណឹងល្អយ៉ាងពិតប្រាកដ ដោយសារមានមនុស្សយ៉ាងច្រើនមិនទាន់ស្គាល់ព្រះជាម្ចាស់ មនុស្សជាច្រើនបានទន្ទឹងរង់ចាំសេចក្តីសង្ឃឹមមួយនៅក្នុងដួងចិត្តរបស់គេ យើងដឹងថាសេចក្តីសង្ឃឹមនេះ គឺព្រះយេស៊ូផ្ទាល់៕ អាម៉ែន។